រាជបណ្ឌិត្យសភាកម្ពុជា

# «ទមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១

## ភាគទី៨

អត្ថបទចងក្រងដោយ៖ លោកស្រី **ស៊ីន ច័ន្ទអមរា**
មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា



ប្រភព : https://sopheak.wordpress.com/2015/11/30

បន្ទាប់ពីលោកដុកទ័រវ៉ាលឡេត(Docteur Vallet)ជាចាងហ្វាងក្រុមសមាគមពួកពិជ័យសង្គ្រាមចាស់បានបញ្ចប់នូវសុន្ទរកថារបស់លោករួចរាល់ នៅក្នុងភាគទី៨នេះយើងសូមលើកយកនូវកម្មវិធីបញ្ចប់នៃពិធីសម្ពោធវិមានរំឭកដល់អ្នកស្លាប់នៅក្នុងសង្គ្រាមលោកលើកទី១ គឺពិធីបង្សុកូលឧទ្ទិសកុសលជូនអ្នកដែលបានទទួលអនិច្ចកម្ម និងក្បួនដង្ហែផ្សេងៗរបស់ក្រុមពិជ័យសង្គ្រាមចាស់។ សកម្មភាពចុងក្រោយនៃពិធីសម្ពោធនេះមានបង្ហាញនៅក្នុងបណ្ណសារស្តីអំពី«បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងក័ម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨)»[1] ដោយមានខ្លឹមសារដើម និងការកែសម្រួលមួយចំនួនដូចខាងក្រោម៖

## ៨-ពិធីបង្សុកូលឧទ្ទិសកុសលជូនអ្នកដែលបានអនិច្ចកម្ម និងក្បួនដង្ហែផ្សេងៗរបស់ក្រុមពិជ័យសង្គ្រាមចាស់

នៅក្នុងនគរដែលមានរាស្ត្រប្រព្រឹត្តតាមផ្លូវធម៌ជាជ្រៅជ្រះ បើដូចជារាស្ត្រខ្មែរធ្វើបុណ្យដូចជាបុណ្យឆ្លងនេះ បើគ្មានលោកសង្ឃជួយផងនោះ ឃើញថាធ្វើខុសអំពីសព្វ១ជង ដែលមិនទាន់ដែលមានសោះនៅឡើយ[2]។ បុណ្យនេះនឹងនៅមានខ្វះទៀត បើមិនបាននិមន្តលោកសង្ឃឱ្យមកជួយផងទេ។ ដូច្នេះបានជាមានលោកសង្ឃ ១០០០អង្គ ទៅប្រជុំគ្នានៅជុំវិញរូបនោះ ចាំទម្រាំតែដល់ពេលវេលានិងទៅសូត្រធម៌នៅជុំវិញជើងកុះដែលតម្កល់រូប គឺសូត្របញ្ជូនទៅមនុស្សដែលមរណៈ។

លោករេស៊ីដង់ជាន់ខ្ពស់បារាំង បូជូវាំង ដែលមិនប្រកាន់សាសនាគួរឱ្យមានសេចក្តីសរសើរនោះ បានអនុញ្ញាតឱ្យពួកតំណាងសាសនាផ្សេងៗ ទៅប្រជុំនៅទីនោះទាំងអស់។ លោកសង្ឃរាជបារាំងនៅស្រុកខ្មែរ១អង្គគ្រងស្បង់ខ្មៅ មានពាក់សញ្ញាសម្រាប់ពិធីបុណ្យសព និងមានលោកសង្ឃ១អង្គទៀតជាជំនួយផងក៏តាំងសូត្រធម៌បង្សុកូល ចាប់ផ្តើមពិធីបុណ្យខាងផ្លូវសាសនា។ បន្ទាប់មកលោកសង្ឃខ្មែរទាំង១០០០អង្គដែលនៅអមជុំវិញរូបនោះក៏តាំងសូត្រធម៌តាមចំណែកខ្លួនឡើង[3]។

---

[1] បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងក័ម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥ ទំព័រ១០៥-១០៧។

[2] «ដែលមិនទាន់ដែលមានសោះនៅឡើយ» មានន័យថា ដែលមិនធ្លាប់មានពីមុនមក ពោលគឺរាល់ពិធីបុណ្យនៅប្រទេសកម្ពុជាតែងតែមានវត្តមានព្រះសង្ឃ។

[3] ក៏តាំងសូត្រធម៌តាមចំណែកខ្លួនឡើង មានន័យថា ក៏តាំងសូត្រធម៌តាមបែបព្រះពុទ្ធសាសនា។

មនុស្សជាច្រើនតាមមើលទាំងសញ្ជឹង ទាំងគោរពប្រណិប័តន៍ជាទីបំផុតបុណ្យខាងសាសនា ដែលមានលោកសង្ឃចាមសូត្រធម៌បង្ហើយ។ ត្រែនិងភ្លេងបាននៅស្ងៀមឈឹងនៅវេលាដែលកំពុងធ្វើបុណ្យខាងសាសនានោះ។ បន្ទាប់មកក៏ផ្លុំខ្លុំខ្សែឡើង ប្រយោជន៍ប្រាប់ឱ្យក្រុមពិជ័យសង្គ្រាមចាប់ដង្ហែឡើង ពួកទាហានជើងគោក ទាហានកាំភ្លើងធំ ទាហានជើងទឹក ទាហានទៀរ៉ៃយ៉េរ[4] ហើយនឹងរថក្រោះបារាំងសម្រាប់វាយលុកតម្រៀបគ្នាស្រួលបួលជាទីបំផុត។ មានលោកសក្តិ៥ បូរ៉ែល ជាអ្នកត្រួតត្រា ក៏ដើរបង្ហាត់យ៉ាងហ័សមានរបៀបរៀបរយល្អនិងក្លៀវក្លាផង នៅមុខបណ្តាជនដែលឈរមើលតាមផ្លូវប៊ូល្លីវ៉ាមីស[5]ហើយសរសើរផង។ នៅពេលដែលក្រុមពិជ័យសង្គ្រាមកំពុងដើរដង្ហែនោះ មានយន្តហោះ២ ហោះលើរូបវិមាន។ យន្តហោះ១គ្រឿងបានហោះបន្ទាបនៅប្រហែលតែ៤-១០ម៉ែត្រពីអ្នកឈរមើល នាំឱ្យមានការភិតភ័យមិនតិចទេ រួចក៏ទម្លាក់ផ្កា១បាច់យ៉ាងល្អធើតនៅជើងរូបវិមាន ហើយសត្វនោះក៏ហើរឡើងទៅលើវិញ ទៅតាមគូកនវានៅកណ្តាលអាកាស ដែលចេះតែហើរមិនឈប់សោះ។

សកម្មភាពទាំងនោះចំណាយអស់ពេលច្រើន ហើយវេលាក៏កាន់តែជឿនទៅមុខ ព្រះអាទិត្យដែលកាន់តែរះខ្ពស់ឡើងៗក៏កាន់តែមានចំហាយក្តៅមែនទែន។ ប៉ុន្តែទោះជាក្តៅប៉ុណ្ណឹងក៏គ្មានបារាំងណា១ ឬអ្នកស្រុកអាយណា១ ដើរចេញពីទីនោះទេ គឺស៊ូនៅមើលមនុស្សសាសន៍ផ្សេងៗ ដែលដើរដង្ហែគ្នាក្រោយពួកទាហានទាល់តែចប់។ ការដង្ហែនេះមិនមែនជាកម្មវិធីមិនសូវសប្បាយក្នុងបុណ្យនោះទេ មានផ្លាជិះប៊ីស៊ីក្លែត[6]តម្រៀបជាជួរ មានដំរីប្រមាណជា៤០ មានចងគ្រឿងកូបដោយវត្ថុមានតម្លៃ ហើយមានពួងស្លៀកពាក់យ៉ាងស្អួចស្តើង(បន្តិចបន្តួច) ដាក់លំពែងចម្បាំងលើស្មាដើរហែហាមសង្ខាងផ្លូវ។

តាមគំនិតលោក បូដូវាំង បុណ្យឆ្លងរូបវិមានសម្រាប់មនុស្សស្លាប់នោះ ត្រូវគិតជាដំបូងបង្អស់អំពីការសម្តែងនូវសេចក្តីកតញ្ញូយ៉ាងធំធេងទៅដល់អ្នកដែលមានគ្រោះដល់ស្លាប់នៅក្នុងចម្បាំងធំនោះ។ បន្ទាប់មក បុណ្យនោះក៏ត្រូវឱ្យមានកត់ត្រាក្នុងសារតារ និយាយអំពីសាសន៍នៅក្រោមអាណាព្យាបាល (ខ្មែរ) និងសាសន៍ដែលទំនុកបម្រុងបានចងជាស្ពានមេត្រីនឹងគ្នា(បារាំង) ឱ្យដឹងថាថ្ងៃនេះហើយដែលយើងរឹតតែមានចិត្តស្រឡាញ់គ្នាទៅវិញទៅមក ទុកចិត្តគ្នាទៅវិញទៅមក ដោយព្រោះតែនឹកទៅដល់ការត

---

[4] ទាហានទៀរ៉ៃយ៉េរ ជាពាក្យបារាំងគឺ Tirailleur ប្រែថាទាហានពិជ័យសង្គ្រាម។

[5] ផ្លូវប៊ូល្លីវ៉ាមីស(Boulevard Miche) គឺមហាវិថីមីស ដែលយកឈ្មោះតាមលោកសង្ឃរាជកាតូលិកបារាំងឈ្មោះមីស (Miche) ដែលបានគង់នៅឯវិហារកាតូលិកនៅពញាពុក្នុងរជ្ជកាលព្រះបាទអង្គដួង។

[6] ប៊ីស៊ីក្លែត ជាពាក្យបារាំងគឺ Bicyclette ប្រែថាទោចក្រយានឬកង់។

ស៊ូដើម្បីការពារសេចក្តីល្អជាមួយគ្នានាគ្រាកន្លងមក។ មិនទាន់មានប្រូក្រាម( កម្មវិធី )បុណ្យណាដែលធ្វើឱ្យបានពេញលេញ និងបានសម្រេចជាងនេះទៅទៀតក៏គ្មាន។

បុណ្យនោះបានថ្កើងរុងរឿងហើយ ចំណែកឯអ្នកដែលទៅមើលទាំងប៉ុន្មាននោះក៏បានរក្សាឫកពារជាអ្នកថ្លៃថ្នូរក្នុងឱកាសនោះ។ អ្នកដែលទៅមើលគ្មានភ្លេចទេថា ថ្ងៃនេះខ្លួនឯងធ្វើបុណ្យខ្មោច ហើយខ្មោចនោះទៀតជាខ្មោចមនុស្សដែលស៊ូវេទនានឹងការណ៍១ធំណាស់ គឺការកាន់គ្រឿងអាវុធទៅប្រយុទ្ធ ដើម្បីភាពស៊ីវីល័យ( អរិយធម៌ )សម្រាប់មនុស្សទាំងជម្ពូទ្វីប។

ការដែលរាស្ត្រស្រុកអាយចំនួនច្រើនម៉ឺន ធ្វើដំណើរមកតាំងពីស្រុកភូមិឆ្ងាយៗ ឯប្រទល់ដែនស្រុកប្រូតិចតូរ៉ាត៍(របបអាណាព្យាបាលគឺប្រទេសកម្ពុជា) ដើម្បីមកជាកិត្តិយសចំពោះដល់មនុស្សរបស់នគរទាំង២ដែលទទួលអនិច្ចកម្មទៅហើយ។ រាស្ត្រទាំងនោះកាន់ឫកពារយ៉ាងហ្នឹង នេះជាតឹកតាងមួយជាសំខាន់ ថាចិត្តខ្មែរឥឡូវនេះរួមចូលគ្នាជាមួយនឹងចិត្តបារាំងសែសពិតមែនហើយ។ មនុស្សដែលមានជាច្រើននឹងគណនាពុំបាននោះ នៅជុំវិញរូបដែលជាងឌូក្វាំង ធ្វើយ៉ាងល្អ ហើយដែលមកទីនេះដោយចិត្តឯងឥតមាននរណាបង្ខំនោះទេ។

ការដែលរាស្ត្រយកតម្រាប់តាមព្រះករុណា ធ្វើបុណ្យឱ្យមនុស្សដែលស្លាប់ក្នុងចម្បាំង ប្រយោជន៍ឱ្យគង់ច្បាស់ជាមួយនឹងបារាំង ដែលប្រជុំគ្នានៅក្រោយលោកឡឺរេស៊ីដង់ សុប៉េរីយ៉ើរ បូឌូវាំង នោះជាការប្រសើរណាស់។

ដូចកាសែតអូពីនីញ៉ុង( Opinion ) ស្រុកព្រៃនគរបាននិយាយក្រោយធ្វើបុណ្យនេះមួយថ្ងៃថា យើងគួរបង្ហាញបុណ្យនេះទៅពួកយីពុន( ជប៉ុន )ដែលមកស្រុកយើងពីម្សិលមិញ និងអ្នកប្រទេសដទៃៗដែលត្រូវជាមិត្តតែមិនសូវជិតស្និទ្ធនឹងយើង ឬត្រូវជាខ្មាំងនឹងយើង ដែលរិះគន់យើងអំពីរបៀបរៀបចំស្រុកចំណុះរបស់យើងនោះ ឱ្យអស់មន្ទិលសង្ស័យ ថារាស្ត្រដែលនៅក្នុងអាណាព្យាបាលយើងពិតជាស្រឡាញ់យើងនិងស៊ូនឹងយើងប្រាកដមែន។

សេចក្តីដែលយើងឃើញកាលបុណ្យឆ្លងរូបនោះ នាំឱ្យយើងបាត់តូចចិត្តនឹងសេចក្តីបន្ទោសរិះគន់ដែលមានមកពីប្រទេសក្រៅនិងមកពីស្រុកយើង។ ថ្ងៃ១ មីនា ឆ្នាំ១៩២៥ នេះជាជាថ្ងៃមួយដ៏ល្អប្រពៃចំពោះនគរបារាំងសែស។

( សូមរង់ចាំអានសេចក្តីសន្និដ្ឋាននៅក្នុងភាគបញ្ចប់! )